# ការសំភាសន៍របស់អ្នកមីង ណៃ ស៊ីណាត

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា        ខៈ អ្នកដែលត្រូវគេសំភាសន៍ ណៃ ស៊ីណាត

## ការសង្ខេបរបស់អ្នកមីង ណៃ ស៊ីណាត

អ្នកមីង ណៃ ស៊ីណាត កើតនៅភូមិបត្តាជី ហើយគាត់បានផ្លាស់ទីលំនៅមកនៅព្រែកហូរវិញ គាត់មានឪពុកដើមដែលគាត់បានស្លាប់កាលពីសម័យ ប៉ុល ពត ហើយម្តាយគាត់ក៏មានស្វាមីមួយទៀត ។ ជីវិតអ្នកមីងពុំសូវមានភាពងាយស្រួលប៉ុន្មានទេ ការរស់នៅរបស់គាត់គឺមានសភាពយ៉ាប់ហើយ គាត់ត្រូវមើលចៅដែលទឹមតែកើតបាន៣ខែហើយត្រូវម្តាយស្លាប់ចោលទៅ បន្ទុករបស់គាត់គឺមានច្រើន ហើយគាត់បានខំពុះពារគ្រប់ទាំងអស់។

កៈ

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតអ្នកមីងនៅក្នុងថ្ងៃនេះហើយពួកយើងសំភាសន៍នៅក្នុងខែមិនា ឆ្នាំ២០១៧ ហើយការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិ ព្រែកហូរខាងលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា។ហើយអឺចឹងនាងខ្ញុំសូមចាប់ផ្តើមធ្វើការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងថា តើជីវិតអ្នកមីងគាត់ជួបរឿងអី គេខ្លះនៅក្នុងជីវិតនឹងអំពីប្រវត្តិរបស់ដូនតារបស់គាត់នឹងរូបគាត់ផ្ទាល់ផងដែរ អ្នកមីងសូមប្រាប់ឈ្មោះពេញអ្នកមីងឈ្មោះអីគេដែរ?

ខៈ ខ្ញុំហោ?

កៈចាំ!!

ខៈខ្លួនខ្ញុំហោ?

ក៖ចាំ!!

ខ៖ ញ៉ុមឈ្មោះយាយណាត។

ក៖ ឈ្មោះណាត?

ខ៖ចាំ!!

ក៖មីងចាំត្រកូលរបស់ខ្លួនឯងទេ?

ខ៖ ត្រកូល អោម ណាត។

ក៖ ចាំហ្នឹងហើយ អ៊ីចឹងអ្នកមីងសព្វថ្ងៃមានអាយុប៉ុន្មានហើយ?

ខ៖ ញ៉ុម ញ៉ុម៥០ជាងហើយ។

ក៖ ៥០ជាងណាទេក្មេងម្ល៉េះ!!ឃើញយូរណាស់ហើយហ្នឹងហាំ!!

ខ៖ ៥០ជាងមីអូន។

ក៖ ៥០ប៉ុន្មានអោយប្រាកដមើល!!

ខ៖ ៥២។

ក៖ ៥២ហោ?

ខ៖ ហ្នឹងហើយ។

ក៖ មីងចាំថាខ្លួនឯងកើតនៅក្នុងថ្ងៃខែឆ្នាំណាអត់?

ខ៖ ញ៉ុមអត់ចាំ ប្ដីញ៉ុមយកទៅណោះ សំបុត្រកំណើតនៅគាត់។

ក៖ អ៊ីចឹងអត់ដឹងថាខ្លួនឯងកើតនៅឆ្នាំណាទេ!!គ្រាន់តែដឹងខ្លួនឯងហ្នឹងអាយុ៥២ឆ្នាំហើយ!!

ខ៖ចាំ!!

ក៖ មីងដឹងថាស្រុកកំនើតខ្លួនឯងកើតនៅណាអត់?

ខ៖ នៅបត្តាជី។

ក៖ មើលប្រាប់ឈ្មោះអោយពេញមើល ភូមិបត្តាជី ឃុំអីគេដែរ?

ខ៖ ឃុំអីគេទេ!!

(កូន)៖ ឃុំតាខ្មៅ។

ក៖ ព្រៃកហូរហើនៅបត្តជី?នៅភូមិបត្តាជី ឃុំបត្តាជី ស្រុកតាខ្មៅ ខេត្តកណ្តាល?

ខ៖ ចា៎!!

ក៖ ហ្នឹងហើយ អ៊ីចឹងមីងពេលមុនអត់ទាន់នៅនេះណាហី?

ខ៖ មិនទាន់នៅនេះទេ ញ៉ុមនៅបត្តជីហ្នុ៎!!

ក៖ ចា៎ហើយម៉េចបានប្តូរទីលំនៅមកនៅបត្តាជីវិញ?

ខ៖ ញ៉ុមចង់មកនៅជាមួយម៉ែញ៉ុមញ៉ុមមកនៅបត្តាជីទៅមកនៅនេះវិញ(ព្រៃកហូរ)!!

ក៖ ចា៎អ៊ីចឹងហោ?ខ៖ចា៎!!ក៖អ៊ីចឹងដោយសារតែមកចង់នៅជិតម៉ែបានមកនៅនេះវិញមីងហ្នុ៎?

ខ៖ ហ្នឹងហើយ!!

ក៖ អ៊ីចឹងមីងសំរាប់កើតឆ្នាំខ្មែរមីងកើតឆ្នាំសត្វអីគេវិញ?គេហៅឆ្នាំអីគេ?

ខ៖ ញ៉ុមអត់ដឹងដែរថារឿងសត្វ!!

ក៖ ដូចរបៀបថាឆ្នាំជូត ឆ្លូវអីវ៉ាន់ហ្នុ៎មីងកើតឆ្នាំអីគេវិញ?

ខ៖ ឆ្នាំបែបឆ្នាំជូតទេនេះ!!

ក៖ ជូតហោ ?

ខ៖ចា៎!!

ក៖អត់ច្បាស់ទេហី?

ខ៖ ដូចឆ្លូវហោ?

ក៖មើលរកនឹកតិចមើលឆ្នាំខ្លួនឯងឆ្នាំខ្មែរកើតឆ្នាំសត្វអីគេ?ដោយសារឆ្នាំខ្មែរមានទាំង១២ហ្នំអ្នកមីងមានជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់អីអញ្ចឹងទៅណាស់!!

ខ៖ ដូចសេះ សេះហើយ។

ក៖ អញ្ចឹងឆ្នាំសេះហោ?

ខ៖ ចាំសេះ!!

ក៖ អ៊ីចឹងមមី។

ខ៖ មមី។

ក៖ ចាំអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមហោ?

ក៖ចាំ!!!

ខ៖ ញ៉ុមបងប្អូនម៉ាផ្ទះញ៉ុមតើហី?

ក៖ ទាំងបងប្អូនជាមួយ បងប្អូនមីងបង្កើតហាំ?

ខ៖ ប្អូនបង្កើតហោ?

ក៖ចាំ!!!

ខ៖ អានាង មីភណ្ឌ៍ !!

ក៖ចាំ!!

ខ៖ ៨នាក់។

ក៖អ៊ីចឹងអ្នកណាគេមួយទៀត?

ខ៖ អានាង។

ក៖ ពូនាង មីងភណ្ឌ័ មីងហើយអ្នកណាគេម្នាក់ទៀត?

ខ៖ នៅប្អូនញ៉ុមមួយទៀត ហ៊ីបងញ៉ុមមួយទៀតមីណូ។

ក៖ ឈ្មោះណូ?

ខ៖ណូ!!

ក៖ហ្នឹងហើយទំរាំតែនិយាយចេញ ភ្លេចច្រើនមីងហោ?

ខ៖ ចាំចាំភ្លេចច្រើន។

ក៖ ហ្នឹងហើយ
អ៊ីចឹងមីងបងប្អូនមីងទាំងបួននាក់ហ្នឹងរាល់ថ្ងៃគាត់នៅរស់ទាំងអស់ឬក៏គាត់ស្លាប់ខ្លះហើយ?

ខ៖ ស្លាប់អស់ខ្លះហើយ ។

ក៖ ស្លាប់អ្នកណាគេវិញ?

ខ៖ ចៅ កូនគាត់នឹងមួយ។

ក៖ មិនមែនទេបងប្អូនមីង៤នាក់ហ្នឹងហាំ?

ខ៖ ចាំ!!

ក៖ អ៊ីចឹងពូនាងនៅរស់មីងនៅរស់ហើយនឹងមីងភណ្ឌ័នៅរស់ ហើយពូណូនោះ?

ខ៖ នៅរស់ដែរ។

ក៖នៅរស់ដែរអ៊ីចឹង៤នាក់នៅរស់ទាំង៤នាក់?

ខ៖ចាំ!!

ក៖ហ្នឹងហើយ ហើយឥឡូវពួកគាត់នៅជិតៗមីងទាំងអស់ហ្នឹងហោ?

ខ៖ ហ្នឹងហើយ ជិតទាំងអស់។

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ មីងលេងអីគេខ្លះជាមួយបងប្អូន?

ខ៖ អត់លេងអីមិនដែលលេងអីផង។

ក៖ ម៉េចថាមិនដែលលេងអី?មានដែលលេងគប់វង់លេងអីជាមួយគ្នាអត់?

ខ៖ ដែលគប់តើ!!

ក៖ មើលនិយាយប្រាប់តិចមើលកុំលាក់អីណា!!

ខ៖ អត់អីទេ!!វាដែលលេងគប់ដែរ លេងគប់វង់ដែរ!!

ក៖ លេងអីគេខ្លះទៀត?

ខ៖ ញ៉ុមអត់ចេះគប់វង់ទេ គ្រាន់តែឆ្កឹះកៅស៊ូឆ្កឹះអីហ្នឹងហាំ!!

ក៖ ហ្នំឥឡូវក្រៅពីឆ្កឹះកៅស៊ូហ្នឹងមានលេងអីគេទៀតអត់?

ខ៖ អត់លេងអីទេ!!

ក៖ មីងពេលអ្នកមីងនៅពីទូចដូចជាគ្រួសារមីងគាត់ធ្វើអីគេដែរដើម្បីចិញ្ចឹមបងប្អូនអីវ៉ាន់ហ្នំ??

ខ៖ គាត់ថាគាត់ចិញ្ចឹមគាត់ថាទៅរកឃ្មុំទៅរកអីមក
អើរទៅរកឃ្មុំដើរទៅរកឃ្មុំពីណោះមកចិញ្ចឹមទៅ។

ក៖ចាំ!!

ខ៖ គាត់ពេលនៅរស់ដើររកចិញ្ចឹមឃ្មុំរកអីទៅ!!

ក៖ អញ្ចឹងបងប្អូនរបស់អ្នកមីងខ្លះដើររកឃ្មុំជាមួយម៉ែឪដែរអញ្ចឹងហោ?

ខ៖ ហ្នឹងហើយ។

ក៖ ហើយបានច្រើៗអត់មីងឃុំ?

ខ៖ ហ្វូបានមួយកញ្ជើរអីរ៉ាន់ហ្វូ!! មួយកំនរប៉ុនៗនេះទៅចេះយកមកដោះស្រាយចិញ្ចឹមទៅ!!

ក៖ហ្វូ!!

ខ៖ចាំ!!

ក៖ មីងតាំងពីមីងមកនៅព្រៃកហូរនេះតាំងពីឆ្នាំប៉ុន្មានវិញមីងដឹងទេ?

ខ៖ ញ៉ុម ញ៉ុមអត់ចាំអាឆ្នាំហ្នឹងញ៉ុមអត់ដែលចាំទេបង!

ក៖ អត់ចាំទេអ៊ីចឹងហោ?

ខ៖ចាំ!!

ក៖ តែដឹងថាយូរណាស់ហើយហោ?

ខ៖ចាំ!!ពេលយូរហើយ!!

ក៖ចាំ!!

ខ៖ យូរហើយ!!

ក៖ មីងសំរាប់បងប្អូនរបស់មីង មីងស្រលាញ់អ្នកណាគេជាងគេ?

ខ៖ចាំ??

ក៖ ស្រលាញ់អ្នកណាជាងគេបងប្អូន?

ខ៖ ខ្ញុំហោ?

ក៖ចាំ!!

ខ៖ រាល់ថ្ងៃញ៉ុមស្រលាញ់អានាង។

កៈ ស្រលាញ់ពូនាងជាងគេ?

ខៈ ចា៎!!

កៈ ចឹបានស្រលាញ់មួយហ្នឹងជាងគេ ចឹបានអត់ស្រលាញ់ស្មើគ្នា?

ខៈ ដឹងអីហ្ន៎!!

កៈ អ៊ត់ដឹងដែរ!!ម៉េចដែរបនាមីងស្រលាញ់ពូនាងដូចជាអីជួយមីងច្រើនឬក៏ម៉េច?

ខៈ ដូចហ្នឹងប្អូនញ៉ុមបង្កើត។

កៈចា៎!!

ខៈ ប្អូនបង្កើត។

កៈ ហើយជួយមីងជួយអីអញ្ចឹងទៅណោស?

ខៈចា៎!!ជួយញ៉ុមអីអញ្ចឹងទៅ!!វាកូនញ៉ុមឈឺទៅវាទៅជួយអីឈឺទៅណាស់។

កៈចា៎!!

ខៈអោយលុយមើលវាទៅណាស់ឥឡូវវា វាស្លាប់បាត់ហើយ។

កៈ កូនមីងហ្នឹងហោ?

ខៈ ស្លាប់បាត់ហើយ នៅតើនេះ ញ៉ុមនៅអាចៅនេះ ញ៉ុមមើលចៅរាល់ថ្ងៃហា៎!!

កៈចា៎!!ខៈអត់មានអ្នកណាគេមើលញ៉ុមមើលចៅហ្នឹងរាល់ថ្ងៃទៅ!!

កៈ កូនមីងស្លាប់។

ខ ៈស្លាប់បាត់ហើយហ្នឹង!!ឥឡូវមើលចៅ មើលចៅ !!!ស្លាប់បាត់ហើយ
អ៊ត់បានទៅណាទៅអី!!មើលតែចៅហ្នឹងរាល់ថ្ងៃហិ!!នៅនៅរាល់ថ្ងៃនេះ អត់មើលអីទេ!!

កៈ អ៊ីចឹងអ្នកមីងសំរាប់ឪពុករបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ ចាំ?

ក៖ឪពុកហាំ?

ខ៖ ញុំមអត់មាននេះទេ ទេឪពុកញុំមឈ្មោះអីគេភ្លេចឈ្មោះគាត់ហើយ!!

(កូន)៖ តាណៃ?

ខ៖ មិនមែនទេមួយទៀត!!

ក៖ តាណៃហ្នឹងគ្រាន់តែជាម៉េចដែរ?

(កូន)៖ តា!!

ខ៖ គាត់មិនមែនជាឪពុកបង្កើតទេ!!

ក៖ ហ្ហំអឺចឹងតាណៃមិនមែនជាឪពុកបង្កើតទេហេ?

ខ៖ ចាំ!!

ក៖ ចុះឪពុករបស់មីងបង្កើតនោះឈ្មោះអីគេវិញ?

ខ៖ ញុំមភ្លេចហើយ ឈ្មោះអីគេញុំមភ្លេចហើយ!!!

ក៖ ភ្លេចឈ្មោះឪខ្លួនឯង?

ខ៖ ឪខ្លួនឯងស្លាប់ហើយហ្នឹងហាំ!!

ក៖ ស្លាប់តាំងពីមីងនៅប៉ុន្មាន?

ខ៖ ធំហើយហ្នឹង!!តូចៗហើយញុំមអត់ចាំ។

ក៖ រាងនៅស្ទើរៗអឺចឹងមីងហេ?

ខ៖ ចាំ!!

ក៖ (សួរទៅប្អូនគាត់ដែលឈ្មោះភណ្ឌ័) មីងភណ្ឌ័ឪឈ្មោះអីគេវិញមិនមែនឈ្មោះតាណៃហ្ហំ?

(ប្អូនស្រីគាត់)៖ចាំ?

ក៖ ឪពុកមីងឈ្មោះអីគេ?

(ប្អូនស្រីគាត់)៖ ឪពុកខ្ញុំ?

ក៖ចាំ!!

(ប្អូនស្រីគាត់)៖ តាដុស។

ក៖ តាដុស?

(ប្អូនស្រីគាត់)៖ចាំ!!

ក៖ អ៊ីចឹងអ្នកមីងអត់ចាំឈ្មោះឪពុកបង្កើតរបស់ខ្លួនឯងទេហោ?

ខ៖ ចាំ!!

ក៖ ចាំតែឈ្មោះឪពុកក្រោយទេហី?

ខ៖ ហ្នឹងហើយក្រោយ!!

ក៖ ហ្នឹងហើយ!!អ៊ីចឹងឪពុកក្រោយរបស់អ្នកមីងឈ្មោះតាណៃមីងណោះ?

ខ៖ ចាំ!!

ក៖ នៅក្នុងសំបុត្រកំណើតរបស់អ្នកមីងឈ្មោះតាគាំម ណៃ គាត់កើតនៅថ្ងៃសៅរ៍ទី៩ខែមិនា ឆ្នាំ១៩២៥ នៅភូមិឆ្នាពួន ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា។ហ្នឹងសំរាប់ឪពុកចុងរបស់អ្នកមីងទេ!!តែមិញប្អូនមីងបានប្រាប់ឈ្មោះអីគេអត់ចាំដែរ។ អ៊ីចឹងអ្នកមីងសំរាប់ឪពុករបស់អ្នកមីង ឪពុកមុនគាត់ស្លាប់ចឹមីង?

ខ៖ គេយកទៅ អាពតយកទៅ។

ក៖ ហ្វ៎អ៊ីចឹងគាត់ស្លាប់នៅក្នុងជំនាន់ប៉ុល ពតទេអ៊ីចឹង?

ខ៖ ហ្នឹងហើយ គេយកទៅ។

កៈ ម៉េចខ្លះមីងពេលគេយកទៅ?

ខៈ ញុំមអើរគេយកបាញ់ចោលគេយកសម្លាប់ចោល
ញុំមយកបានទៅគេអត់អោយបាយស៊ីគេយកទៅសម្លាប់ចោលទៅ!!គេយកវៃចោលទៅ
ថាហ៊ីអញយកទៅដល់ហើយអញយកទៅដល់ហើយ
អញយកសម្លាប់ចោលហើយអត់អោយស៊ីបាយទេហើយបងមួយទៀតឈ្មោះ
មួយទៀតយកទៅសម្លាប់ដែរ យកទៅដែរ យកទៅទាំង២នាក់
ហើយឪពុកមួយបងមួយសម្លាប់ចោលឈ្មោះណាម!!

កៈចាំ!!

ខៈ យកសម្លាប់ចោលអស់ហើយ យកសម្លប់ចោលទាំងអស់ ២នាក់ទេយកសម្លាប់ចោល!!

កៈ ហ្នឹងសំរាប់ឪពុកបង្កើតអ្នកមីងហោ?

ខៈ ចាំ!!ហ្នឹងហើយ ។

កៈ តែអ្នកមីងអត់សូវចាំឈ្មោះគាត់ទេហោ?

ខៈ ចាំ!!

កៈចាំ!!អ៊ីចឹងចាំតែឪពុកចុងនេះទេ!!

ខៈចាំ!!

កៈ
អញ្ចឹងសំរាប់តើអ្នកមីងមានអនុស្សាវរីយ៍អីគេខ្លះជាមួយឪពុករបស់អ្នកមីងពេលគាត់នៅរស់ហាំ??

ខៈ នៅរស់ហោ?

កៈចាំគាត់ជាឪពុកម៉េចដែរ?

ខះ ឪពុកគ្រាន់ថាយើងគាត់អោយ
គាត់អោយយើងគាត់អោយដីហ្នឹងអោយយើងនៅទេ!!កះចាំ!!ខះស្រាប់តែគាត់អោយដីយើងនៅនៅផ្ទះហ្នឹងទេ!!

កះ តាឪពុកបង្កើតឬក៏តាណៃ?

ខះ តាណៃ។

កះតាណៃអ្នកអោយទេអញ្ចឹង?

ខះចាំ!!

កះនិយាយពីអនុស្សាវរីយ៍ពីឪពុកបង្កើតហាំ!!តាមុនតាណៃទៀតហ្ន៎?

ខះ ហ្ន៎គាត់ស្លាប់ទៅគាត់អត់មានអោយអីទេ!!គ្រាន់តែថារកគាត់រកអត់ឃើញ។

កះចាំ!!

ខះ ទាល់តែមកណោះបានមានផ្ទះនៅមានឪពុកចុងហ្នឹងទេនេះបានអោយផ្ទះនៅ។

កះចាំ!!

ខះចាំ!!

កះតែឪពុកមុនស្លាប់ដោយសារជំនាន់ប៉ុល ពតបាត់ហើយ!!

ខះចាំ!!

កះអ៊ីចឹងសំរាប់តាណៃគឺជាឪពុកចុងរបស់មីង នេះគឺជាសំបុត្រមរណភាពរបស់តាណៃទេ!!

ខះចាំ!!

កះអ៊ីចឹងគាត់ត្រូវជាប់ដោយសារគាត់បានមើលថៃមីងទេណោះ?

ខះចាំ!!ហ្នឹងហើយ!

កៈអ៊ីចឹងតាណៃគាត់ស្លាប់នៅថ្ងៃអាទិត្យទី១០ ខែសីហា ឆ្នាំ២០០៨
ហើយឪពុករបស់តាណៃឈ្មោះពុត គាំ សញ្ជាតិខ្មែរកើតនៅថ្ងៃទី០៧ខែកុម្ភៈ
១៨០៥ចំយូរណាស់ហើយហ្នឹង(គិតថា១៩០៥ទេ ប្រហែលជាគេច្រឡំ)
ហើយម្ដាយតាណៃឈ្មោះលោ អៃ កើតនៅក្នុងថ្ងៃ០១ ខែមករា ឆ្នាំ១៨០៩
អ៊ីចឹងគាត់យូរៗណាស់ហើយ!!(គិតថា១៩០៩ទេប្រហែលជាគេច្រឡំ)
អ្នកមីងនៅសល់សំបុត្រកំណើតរបស់ឪពុកចុងដែរតែគាត់ដូចតែនេះដែរហ្នឹងរបៀបថាគាត់ថែ
ទាំដល់មីងអញ្ចឹងទៅណាស់!!
អ៊ីចឹងអ្នកមីងដូចជាឪពុកគាត់ជាមនុស្សម៉េចដែរគាត់ចិត្តល្អនឹងអ្នកមីងអត់?

ខៈ ចិត្តល្អដែរ។

កៈ ម៉េចខ្លះទៅ?

ខៈ គាត់ចិត្តល្អដែរ ពីមុនខាងគ្រួសារយើងមើលអត់ឃើញ វាអត់យល់
វាគ្រាន់តែថាសុទ្ធតែអាមនុស្សវាអត់ល្អ ថាមនុស្សយើងថាវា វាអត់ល្អ!!

កៈ អ្នកណាគេអត់ល្អ?

ខៈ ឪពុកយើងអត់ល្អដាក់យើង!!

កៈ អើរតាណៃហ្នឹងហេ?គាត់អត់សូវចិត្តបាន តែគ្រាន់តែគាត់ចែកដីចែកអីអោយនៅដែរតើហី?

ខៈ គ្រាន់តែយើងមិនមែនកូនគាត់!! ខ្ជិលនិយាយណាស់ តែនិយាយទៅណែនទ្រូង!!

កៈ ម៉េចអ៊ីចឹងវិញ?គាត់អត់សូវស្រលាញ់មីងអញ្ចឹងទៅណោះ?

ខៈចាំ!!

កៈអញ្ចឹងឥឡូវងាកចូលដល់ ដោយសារទឹមតែរកឃើញសំបុត្រកំណើតរបស់អ្នកមីង!!

ខៈចាំ!!

កៈ អញ្ចឹងអ្នកមីងអត់ដាក់ត្រកូលអោមទេ អ្នកមីងដាក់ត្រកូលណៃ ស៊ីណាត!!ខៈចាំ!!កៈ
នៅក្នុងសំបុត្រកំណើត អញ្ចឹងអ្នកមីងកើតនៅក្នុងថ្ងៃព្រហស្បត៍ទី២៧ ខែមិនា ឆ្នាំ១៩៧៤

នៅភូមិបត្តាជី ឃុំតាខ្មៅ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា។អញ្ចឹងដោយសារពេលមុនស្រុកភូមិហ្នឹងគេដាក់អញ្ចឹងតែឥឡូវត្រូវបានប្ដូរហើយ ប្ដូរទៅជាក្រុងតាខ្មៅវិញ ។

ខ៖ចាំ!!

ក៖លែងស្រុកកណ្ដាលស្ទឹងដូចមុនហើយ ចាំ!!ហ្នឹងហើយ អញ្ចឹងឪពុករបស់អ្នកមីងឈ្មោះគាំណៃ អញ្ចឹងបាននិយាយពេលមុនហើយ
អូខេអញ្ចឹងមិញបានដឹងពីថ្ងៃខែឆ្នាំកំនើតរបស់អ្នកមីងហើយ!!អញ្ចឹងចូលដល់ម្ដាយរបស់អ្នកមីងវិញម្ដង អញ្ចឹងម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរអ្នកមីង?

ខ៖ ហ៊ឺ!!ម្ដាយញ៉ុមឈ្មោះយាយណាង។

ក៖ អញ្ចឹងម្ដាយមីងមើលនៅក្នុងសំបុត្រកំណើតឈ្មោះ សៅ សំណាង សញ្ជាតិខ្មែរ
កើតនៅថ្ងៃទី០៦ ខែកុម្ភៈឆ្នាំ១៩៣៩
អញ្ចឹងទីកន្លែងកំណើតរបស់ម្ដាយអ្នកមីងកើតនៅភូមិស្រុកចេក ឃុំជើងឯក ស្រុកដង្កោ ខេត្តកណ្ដាល
ប្រទេសកម្ពុជា!!ប៉ុន្តែឥឡូវស្រុកភូមិហ្នឹងគេបានផ្លាស់ប្ដូរមកជាទីក្រុងភ្នំពេញវិញហើយមីងណោះ?

ខ៖ចាំ!!

ក៖ហ្នឹងហើយ
ចាំអញ្ចឹងអ្នកមីងសំរាប់ម្ដាយរបស់អ្នកមីងគាត់កើតឆ្នាំខ្មែរមីងដឹងថាគាត់កើតឆ្នាំសត្វអីគេអត់?

ខ៖ ញ៉ុមអត់ដឹងដែរ!!

ក៖ អត់ចាំទេមីងណោះ?

ខ៖ អត់ចាំ។

កៈ អញ្ចឹងនៅក្នុងសំបុត្រកំណើត
ហាសំបុត្រមរណរបស់ម្ដាយរបស់អ្នកមីងក៏គេមានដែរហោ!!ហ៊ីអត់ទេគេមានតែសំបុត្រកំណើតទេ!!

ខៈចាំ!!

កៈ
ហ្នឹងហើយចាំអ៊ីចឹងអ្នកមីងសំរាប់អនុស្សាវរីយ៍ដែលអ្នកមីងមានជាមួយម្ដាយហាំម៉េចមីងរៀបរាប់អោយអស់មើលម្ដាយមានចរិកយ៉ាងម៉េចដែរ អ្នកមីងរៀបរាប់អោយអស់មើល?

ខៈ ចរិក!!

កៈ ម្ដាយរបស់មីងហាំ?

ខៈ ម្ដាយហោ?

កៈចាំ!!

ខៈ វាមាននៅអានិតញ៉ុម!!

កៈ ម៉េចដែរមីង?

ខៈ គាត់អានិតញ៉ុមជាងគេ គាត់អត់ចោលញ៉ុមទេ
គាត់ថាអានិតណាស់!!ឃើញញ៉ុមវាអត់ដឹងអីគាត់ថាអានិតជាងគេ!!

កៈចាំ!!

ខៈអានិតញ៉ុមជាគេ ដូចប្អូនញ៉ុមអាពៅហ្នឹងក៏អានិតញ៉ុមដែរ អានិតទាំងអស់
អានិតញ៉ុមជាងគេខ្លាចគេធ្វើបាប!!

កៈ ចាំហ្នឹងហើយ!!

ខៈគេធ្វើបាបញ៉ុមគេថា វាអានិតជាងគេម៉ង!!

កៈ ហើយអ្នកមីងម្ដាយអ្នកមីងគាត់រកស៊ីអីគេដែរពេលគាត់នៅរស់ហាំ?

ខ៖ កាល កាលមុនគាត់លក់នំបញ្ចុក
លក់នំបញ្ចុកហាំ!!លក់នំបញ្ចុកនៅព្រៃកហូរយើងហ្នឹង!!លក់នំបញ្ចុក !!

ក៖ មានអីគេទៀតទេ?

ខ៖ អត់មានអីទៀតទេ មានតែលក់នំបញ្ចុកហ្នឹង។

ក៖ តែដូចមីងពេលមុនម្តាយរបស់អ្នកមីងគាត់រកស៊ីអូសទឹកអូសអីដែរមែនទេ?

ខ៖ ហ្នឹងហើយរកស៊ីអូសទឹក។

ក៖ តាមញ៉ុមអើរទាន៉ពេលមុនអញ្ចឹងហាំ!!

ខ៖ហ្នឹងហើយគាត់អូសទឹក ។

ក៖ អញ្ចឹងមីងពេលមុនម៉េចបានអើរឈប់
គ្រួសារមីងថីបានឈប់អូសទឹកលក់ទៅថីបានអញ្ចឹង?

ខ៖ គាត់ គាត់ចាស់ហើយគាំតស្លាប់ហើយគាត់លែងបានអូសទឹកហើយ!!

ក៖ តែអត់មានអ្នកណាគេតពីហ្នឹងណាហី?

ខ៖ អត់ត អត់មានផង ។

ក៖ចាំ!!

ខ៖ អត់មានអ្នកណាតទេមីអូន!!

ក៖ ចុះអ្នកមីងម្តាយរបស់អ្នកមីងហាំ ជីវិតរបស់គាត់ម៉េចដែរដូចជាចិញ្ចឹមទូន្មានអ្នកមីងហាំ?

ខ៖ កាលមុនគាត់អូសទឹក
គាត់អូសទឹកលក់ទៅថាគាត់ដើរអូសទឹកលក់អីមួយចប់អញ្ចឹងទៅ!!ហើយគាត់ឈប់អូសទៅ
គាត់ឈឺរ៉ាំរ៉ៃៗ លែងគាត់អត់បានទៅអូសទឹក គាត់ឈឺ ចេះតែឈឺចុះឈឺឡើង
គាត់អត់បានអូសទឹកទេ ថាហ៊ីអញអូសទឹកអត់រួចទេ!! លែងអូសទឹកទៅ។

ក៖ មីងមូលហេតុអីបានយាយណាងគាត់ស្លាប់ដែរ?

(កូន)៖គាត់ឈឺ។

ខ៖ គាត់ឈឺ។

ក៖ អញ្ចឹងជំងឺអីគេវិញ?

ខ៖ ជំងឺជំងឺដូចអ្នកកន្លែងនេះវាណែនកន្លែងហ្នឹងហាំ!!\

ក៖ចាំ!!

ខ៖ គេរ៉ៃ រ៉ៃអត់កើតណាស់!!

ក៖ ហ្នំអីចឹងកើតរើមហេ?

ខ៖ កើតរើមហាំ!!

(ប្អូនស្រីគាត់)៖ រ៉ៃអត់កើតដុតអត់កើត!!

ខ៖ គាត់កើតកន្លែងហ្នឹងចេះតែមើលគាត់ទៅ!!មើលអត់កើត!!

(ប្អូនស្រីគាត់)៖ អុជពេញខ្លួន។

ខ៖ រួចស្លាប់បណ្ដោយ ក្ដៅពេក។

ក៖ ចាំដោយសារជំងឺហ្នឹងវាពិបាកមីងណោះ?

ខ៖ ចាំ!!

ក៖ ចាំ!!អញ្ចឹងអ្នកមីងសំរាប់ចំនុចណាដែលអ្នកមីងស្រលាញ់ម្ដាយជាងគេ?

ខ៖ គ្រាន់តែគាត់ស្លាប់គាត់ស្រែកហៅថាកូនថាអញ្ចេកកូនអើយ អញស្លាប់ហើយ អញអត់បានស្រែកហៅកូនឯងទេស្រែកហៅបានមួយគាត់ស្លាប់ទៅ។

ក៖ ស្រែកហៅឈ្មោះមីងហ្នឹងអីចឹងទៅហេ?

ខ៖ចាំ!!

កះហើយកន្លែងណាដែលមីងស្រលាញ់គាត់ជាងគេ ដូចជាគាត់ស្រលាញ់មីងម៉េចដែរ?

ខះ ស្រលាញ់ត្រង់តែស្រែកហៅហ្នឹង។

កះ គ្រាន់តែអញ្ចឹងទេហេ?

ខះចាំ!!

កះអញ្ចឹងនៅពីក្មេងមកគាត់ថៃទាំងមីងបានល្អតើមែនទេ?

ខះ ល្អតើកូន!!

កះ ចាំ!!ឥឡូវមីងចូលដល់នេះវិញម្តង យាយអ្នកមីងខាងម្តាយ យាយគាត់ឈ្មោះអីគេដែរយាយ?

ខះ ក្នុងហ្នឹងហា!!

កះ មីងអត់ចាំឈ្មោះយាយទេហី?

ខះ អត់ចាំទេ។

កះអត់ចាំទេ អ៊ីចឹងនៅក្នុងសំបុត្រកំណើតរបស់ខាងម្តាយរបស់អ្នកមីង ម្តាយខាងលោកយាយសំណាងហ្នឹង យាយឈ្មោះហែម យ៉ុម ហ្នឹងហើយយាយឈ្មោះហែម យ៉ុម កើតនៅក្នុងថ្ងៃទី០៣ខែមេសា ឆ្នាំ១៨១៥(ប្រហែលជាគេសរសេរខុស ១៩១៥ទេមើលទេបើតាមគិត)អូយយូរហើយហ្នឹង ចាំ!!អញ្ចឹងគាត់កើតនៅក្នុងភូមិស្រុកចេក ឃុំជើកឯក ស្រុកដង្កោ ខេត្តកណ្តាល ប្រទេសកម្ពុជាអញ្ចឹងនៅក្នុងសំបុត្រកំណើតគេបញ្ជាក់ប្រាប់ថាអញ្ចឹង។

ខះចាំ!!

កះ ហ្នឹងហើយអញ្ចឹងសំរាប់យាយ មីងកើតទាន់យាយខាងម្តាយទេ?

ខះ កើតទាន់គាត់ដែរ មើលទៅគាត់!!

កះ ម៉េចវិញទៅមីង?

ខ៖ គាត់បត់ជើងបត់ដៃអីញ៉ុមមើលគាត់ គាត់ស្លាប់ហើយលើដៃញ៉ុមដែរ គាត់ស្លាប់ទៅ ។

ក៖ ហ្នំយាយរបស់មីងហ្នឹងហោ?

ខ៖ចា៎!!!

ក៖ ហើយមានអីគេទៀតដែលមីងចាំពីយាយទេ?

ខ៖យាយគ្រាន់ថាអញ្ចេកអត់មានអ្នកណាមើលញ៉ុមមើលគាត់ទៅ
គាត់ស្លាប់បាត់ទៅគាត់ថាអញស្លាប់ហើយលើកទុកលើកដាក់អោយអញផង
គ្រាន់តែប៉ុណ្ណឹងគាត់ស្លាប់បាត់ទៅ។

ក៖ ចា៎អញ្ចឹងអ្នកមីងសំរាប់ចូលដល់តាអ្នកមីងវិញមម្តង
អញ្ចឹងនៅក្នុងសំបុត្រកំណើតបានប្រាប់ថាតារបស់អ្នកមីងឈ្មោះអ៊ុំ
សៅ!!កើតនៅថ្ងៃទី០២ខែមិនាឆ្នាំ១៨១០(ប្រហែលជាគេសរសេរខុសព្រោះបើតាមគិតទៅមិនចំ
ជាឆ្នាំហ្នឹង ប្រហែលជា១៩១០) នៅភូមិស្រុកចេក ឃុំជើងឯក ស្រុកដង្កោ ខេត្តកណ្តាល
ប្រទេសកម្ពុជា មីងកើតទាន់តាសៅហ្នឹងហោ?

ខ៖ អត់ដែលអត់ជួបផង។

ក៖ អត់ដែលស្គាល់គាត់ទេមីងហោ?

ខ៖ ចា៎!!

ក៖ ហើយម៉េចដែរមីង ម៉ែមានដែលប្រាប់អីពីតាទេ?

ខ៖ អត់អត់ដែលប្រាប់ផង។

ក៖ អញ្ចឹងអត់ដែលបានប្រាប់អីពីតាទេអញ្ចឹងណោះ?

ខ៖ ចា៎!!មានតែឃើញសំបុត្រគាត់ប៉ុណ្ណឹងម៉ង!!

ក៖ ហ្នឹងហើយមានតែឃើញសំបុត្រគាត់ប៉ុណ្ណឹងម៉ងហ្នឹង!!! ដឹងថាដូនតាខាងហ្នឹងមក
ដូចជាយាយខាងហ្នឹងអញ្ចឹងហា៎ យាយយ៉ុមម៉េចហា៎ មីងមានដឹងថាគាត់រកស៊ីអីគេអត់
ពីមុនមក?

ខ៖ យាយយ៉ុមគាត់លក់បាត់ហើយហ្នឹង គាត់លក់ផ្ទះបាត់ហើយហ្នឹង។

ក៖ដឹងហើយតែធ្លាប់រកស៊ីអីគេពេលមីងកើតមកហាំគាត់រកស៊ីអីគេដែរ?

ខ៖ គាត់ថារវល់ គាត់ថាគាត់នៅណោះគាត់អត់លក់អីផងហ្នឹង។

ក៖ អ់តលក់អីផងហោ?

ខ៖ចាំ!!

ក៖ អញ្ចឹងគាត់ជាស្ត្រីមេផ្ទះមីងណោះ?

ខ៖ ចាំ!!

ក៖ ចាំអញ្ចឹងតាអីក៏អ្នកមីងអត់ដឹងដែរ?

ខ៖ចាំ!!

ក៖ ហ្នឹងហើយ អ៊ីចឹងចូលដល់ជីដូនជីតាខាងឪពុកអ្នកមីងវិញម្ដង អញ្ចឹងអ្នកមីងអត់ស្គាល់ជីដូនជីតាពិតប្រាកដរបស់ឪពុកមុនទេហោ?

ខ៖ចាំចាំ!!

ក៖ អញ្ចឹងនៅក្នុងសំបុត្រកំនើតមានតែឪពុកម្ដាយរបស់តាណៃទេ!!

ខ៖ចាំ!!

ក៖អញ្ចឹងឪពុករបស់តាណៃគាត់ឈ្មោះលោកតាពុត គាំ កើតនៅថ្ងៃទី០៧ខែកុម្ភ: ឆ្នាំ១៨០៥(ប្រហែលជាខុសគឺប្រហែលជា១៩០៥)នៅ ភូមិ ណាគេអត់បានបញ្ជាក់ទេ!!តែម្ដាយរបស់តាណៃឈ្មោះឡោ អៃ កើតនៅថ្ងៃ០១ មករា ១៨០៩(ប្រហែលជាខុសដែរ ប្រហែលជា១៩០៩ បើតាមគិតទៅ) អញ្ចឹងញ៉ុមអត់ដឹងថាសំបុត្រកំនើតនេះត្រឹមត្រូវឬក៏អត់ទេ ព្រោះដោយសារឆ្នាំមើលទៅគំលាតឆ្ងាយៗពីគ្នា អត់ដឹងទេដោយសារសំបុត្រកំណើតដាក់អញ្ចឹងបើសិនជាត្រូវឬក៏ខុសអត់ដឹងច្បាស់ប្រាកដដែរ ដោយសារមើលទៅវាគំលាតឆ្នាំមើលទៅវាឆ្ងាយៗវាមិនសូវត្រូវប៉ុន្មានទេ។

ខ៖ចាំ!!

ក៖អញ្ចឹងមីងមីងដែលធ្លាប់ឃើញម៉ែឪរបស់តាណៃអីអត់?

ខ៖អត់ដែលផង។

ក៖ អត់ដែលដែល!!

ខ៖ អត់ដែលឃើញផង។

ក៖ អញ្ចឹងអ្នកមីងពេលវេលាដែលអ្នកមីងពិបាកជាងគេនៅក្នុងជីវិតពេលណាដែរ?

ខ៖ ពិបាកពេលយើងរកអីអត់បានអីអត់បានអីចឹងទៅចេះតែដើរដើរទៅ!!

ក៖ ដើរទៅណាវិញមីង?

ខ៖ ចេះតែដើរ ដើរទៅទៅហ្នឹង!!

ក៖ ដើរទៅរកស៊ីបោកគក់អោយគេអញ្ចឹងទៅមីងណោះ?

ខ៖ចាំ!!ពេលណាវាឈឺពេក រាល់ថ្ងៃហ្នឹង ហើយញ៉ុមនេះវាទឹកនោមផ្អែមផង។

ក៖ចាំ!!

ខ៖វាទឹកនោមផ្អែមផងរាល់ថ្ងៃហ្នឹង!!ហើយលេបថ្នាំ ហើយប្តីទិញថ្នាំមកអោយលេបរាល់ថ្ងៃ!!

ក៖ចាំ!!

ខ៖ រាល់ថ្ងៃទឹកនោមផ្អែមផងអីផង រាល់ថ្ងៃហ្នឹង អាលែងមើលថៅផងពិបាកផង
អាផ្ទះហ្នឹងវាមិនទាន់បានធ្វើលិចអស់ហើយ ដំបូលលិចអស់ហើយ!!

ក៖ចាំ!!

ខ៖អត់បានធ្វើ ដំបូលផ្ទះក៏លិចអីក៏លិចដែរ អត់បានធ្វើ ពេលភ្លៀងមក លិចទាំងអស់!!

ក៖ហ៊ើៗ!!

ខ៖ ហូរពីហ្នឹងមកហូរអស់!!

ក៖ លិចផ្ទះលិចអីអញ្ចឹងទៅ?

ខ៖ ចាំ!!

ក៖ចាំអញ្ចឹងអ្នកមីងសំរាប់បងប្អូនរបស់អ្នកមីងទាំងអស់គ្នាមានដែលបងប្អូនណាគាត់ធ្លាប់ទៅរស់នៅប្រទេសក្រៅអីអត់មីង?

ខ៖ អត់ អត់មានផង។

ក៖ នៅតែប្រទេសខ្មែរយើងទេណោះមីង?

ខ៖ចាំ!!ចាំ!!

ក៖ ចាំអញ្ចឹងមីងរស់នៅតែហ្នឹង!!

ខ៖ ចាំ!!

ក៖
មីងដឹងថាប្រវត្តិបងប្អូនដូចជាឪពុកម្តាយរបស់អ្នកមីងអីហ្នឹងគាត់ដែលធ្លាប់ធ្វើស្រែធ្វើអីទេពីមុនមក?

ខ៖ កាលមុនគាត់ធ្វើ ធ្វើដែរហ្នឹង ធ្វើ ធ្វើស្រូវបានច្រើនណាស់ អាអស់
អស់ហ្នឹងសុទ្ធតែធ្វើស្រូវហើយ
(ដីដែលគាត់រស់នៅសព្វថ្ងៃពីមុនជាវាលស្រែដែលគាត់ធ្វើស្រូវ)។

ក៖ វាលផ្ទះមីងហ្នឹងហោ?

ខ៖ ចាំធ្វើស្រូវទាំងអស់។

ក៖ហ្នំ!!

ខ៖ លក់អោយគេហ្នឹង ធ្វើស្រូវបាន បាន មួយហិចតាហ្នំ!!

ក៖ចាំ!!

ខ៖ទាំងអស់ហ្នឹងសុទ្ធតែធ្វើស្រូវទាំងអស់ អញ្ចឹងទឹកដីអ្នកមីងពេលមុនហ្នឹងសុទ្ធតែស្រូវទេ?

ខ៖ ស្រូវទេ។

ក៖ អញ្ចឹងមីងដីរបងខាងនេះដីរបស់មីងដែរអត់?

ខ៖ទាំងអស់ហ្នឹង ម៉ែញ៉ុមលក់អោយគេបាត់ហើយ!!

ក៖ហ្ហ៎!!

ខ៖ធ្វើស្រូវបានច្រើនណាស់ជាងប៉ុន្មាន២ហិចតា។ក៖ចាំ!!ខ៖ ស្រូវច្រើនណាស់។

ក៖អញ្ចឹងពេលមុនមកជីវិតអ្នកមីងក៏មិនសូវពិបាកអីប៉ុន្មានដែរមីងណោះ?

ខ៖ចាំ!!

ក៖ អញ្ចឹងគាត់មានឪពុកម្ដាយគាត់ជាអ្នកមើលថែទាំអីវ៉ាន់អញ្ចឹងទៅ?

ខ៖ចាំ!!ចាំ!!

ក៖ អញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះ អញ្ចឹងអ្វីដែលអ្នកមីងបាននិយាយ ក៏ដូចជាប្រវត្តិរបស់អ្នកមីង កូនចៅរបស់មីងគាត់នឹងបានស្ដាប់ទៅថ្ងៃខាងមុខណាស់អ្នកមីង!!

ខ៖ ចាំ។